# វគ្គប្រជុំទី 1 ស្ដីអំពីភាគីពាក់ព័ន្ធនឹងច្បាប់អាកាសធាតុឆ្នាំ 2024

ថ្ងៃទី 10 ខែមេសា ឆ្នាំ 2025

ការប្រជុំបែបហាយប្រ៊ីដ៖ នៅនាយកដ្ឋានសេវាសាធារណៈនៃទីក្រុង Boston និងការប្រជុំបែបនិម្មិត

ថ្ងៃទី 10 ខែមេសា ឆ្នាំ 2025

# ការរៀបចំសេវាបកប្រែផ្ទាល់មាត់

- **ការបកប្រែភាសាផ្ទាល់មាត់ត្រូវបានផ្ដល់ជូនជាភាសា៖ EEspañol, Português, Kreyòl ayisyen, Kriolu, Tiếng Việt, 普通话, عربي, русский, ខ្មែរ, 한국어, français, និងភាសាសញ្ញាអាមេរិកាំង (ASL)។**
  - ដើម្បីចូលរួមជាភាសាអង់គ្លេស សូមចុចលើរូបតំណាង “Interpretation" ហើយជ្រើសរើសភាសាអង់គ្លេស។
  - Para entrar no canal em português, clique no ícone “Interpretation” e selecione “Portuguese”.
  - Si alguien desea interpretación en español, haga clic en “Interpretation” y seleccione “Spanish”.
  - Pou rantre nan chanèl kreyòl ayisyen an, klike sou ikòn “Interpretation” an epi chwazi “Haitian Creole”.
  - Pa partisipa na Kriolu, klika na íkone "Intirpretason" y silisiona "Cape Verdean Kriolu".
  - 要以普通话参加会议，请单击口语图标并选择 "Chinese”.
  - Để vào kênh bằng tiếng Việt, hãy nhấp vào biểu tượng “Interpretation” và chọn “Vietnamese”.
  - للمشاركة باللغة العربية اضغط على أيقونة "الترجمة الفورية" ثم اختر “Arabic“.
  - Чтобы принять участие на Русский языке, нажмите на ярлык «Устный перевод» и выберите “Russian”.
  - ដើម្បីចូលរួមជាភាសាខ្មែរ សូមចុចរូបតំណាងការបកប្រែផ្ទាល់មាត់ ហើយជ្រើសរើសភាសា "ខ្មែរ"។
  - 한국어로 참여하려면 "통역" 아이콘을 클릭하고 “Korean"를 선택하세요.
  - Pour participer en français, cliquez sur l’icône « Interprétation » puis choisissez « French ».

- **សូមនិយាយយឺតៗ។**
- **គ្រប់អ្នកចូលរួមទាំងអស់ត្រូវតែជ្រើសរើសបណ្ដាញភាសាមួយ ទោះបីជាមើលបទបង្ហាញជាភាសាអង់គ្លេសក៏ដោយ។**



# របៀបវារៈប្រជុំថ្ងៃនេះ

- ម៉ោង 1:00 ៖ កិច្ចស្វាគមន៍
- ម៉ោង 1:05 ៖ ទិដ្ឋភាពទូទៅនៃការបកប្រែផ្ទាល់មាត់
- ម៉ោង 1:10 ៖ ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024
- ម៉ោង 1:30 ៖ បច្ចុប្បន្នភាពពីនាយកដ្ឋានធនធានថាមពល
  - វគ្គសំណួរ និងចម្លើយ
- ម៉ោង 1:50 ៖ ពង្រាងសំណើលើបទប្បញ្ញត្តិនៃនីតិវិធីរបស់ក្រុមប្រឹក្សាភិបាលជ្រើសរើសទីតាំងគ្រឿងបរិក្ខារថាមពល
  - វគ្គសំណួរ និងចម្លើយ
- ម៉ោង 2:35 ៖ សម្រាក
- ម៉ោង 2:50 ៖ ពង្រាងសំណើស្តីពីលក្ខខណ្ឌស្តង់ដាររបស់ក្រុមប្រឹក្សាភិបាលជ្រើសរើសទីតាំងគ្រឿងបរិក្ខារថាមពល
  - វគ្គសំណួរ និងចម្លើយ
- ម៉ោង 3:20 ៖ មតិយោបល់ និងការពិភាក្សាទូទៅ
- ម៉ោង 3:55 ៖ ការបិទបញ្ចប់អង្គប្រជុំ និងជំហានបន្ទាប់

# ការអនុវត្តរបស់ក្រុមប្រឹក្សាភិបាលជ្រើសរើសទីតាំងគ្រឿងបរិក្ខារថាមពល

- ពង្រាងសំណើ/វគ្គប្រជុំភាគីពាក់ព័ន្ធ – **និទាឃរដូវឆ្នាំ 2025**
- សវនាការសាធារណៈស្តីពីបទប្បញ្ញត្តិដែលបានស្នើឡើង – **រដូវស្លឹកឈើជ្រុះឆ្នាំ 2025**
- ការប្រកាសឱ្យអនុវត្តបទប្បញ្ញត្តិ និងសេចក្តីណែនាំ – **ឆ្នាំ 2025 ដល់ដើមឆ្នាំ 2026**
- បទប្បញ្ញត្តិថ្មី – **ថ្ងៃទី 1 ខែមីនា ឆ្នាំ 2026**
- ការដាក់ពាក្យសុំថ្មី – **ថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2026**

# តម្រូវការថាមពលស្អាតក្នុងរដ្ឋ Massachusetts

ថាមពលខ្យល់ **180 MW** ត្រឹមឆ្នាំ 2025

ថាមពលជំនួសពីពន្លឺព្រះអាទិត្យ **4,470 MW** ត្រឹមឆ្នាំ 2025

ថាមពលខ្យល់ **3,650 MW** ត្រឹមឆ្នាំ 2030

ថាមពលជំនួសពីពន្លឺព្រះអាទិត្យ **8,360 MW** ត្រឹមឆ្នាំ 2030

**ថាមពលខ្យល់ទំហំ 24 GW ត្រឹមឆ្នាំ 2050**

ថាមពលជំនួសពីពន្លឺព្រះអាទិត្យ **27+ GW** ត្រឹមឆ្នាំ 2050

**សមត្ថភាពអគ្គិសនីកកើតឡើងវិញនៅក្នុងរដ្ឋ**

សមត្ថភាពថាមពលពីខ្យល់ **113 MW** នៅក្នុងឆ្នាំ 2022

ថាមពលជំនួសពីពន្លឺព្រះអាទិត្យ **3,325 MW** ក្នុងឆ្នាំ 2022

**ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (GHG)**

ការបំភាយឧស្ម័ននៅកម្រិត**សូន្យ**ត្រឹមឆ្នាំ

2021 — 2022 — 2023 — ត្រឹមឆ្នាំ 2025 — ត្រឹមឆ្នាំ 2030 — ត្រឹមឆ្នាំ 2050

**សមត្ថភាពផ្ទុកថាមពល**

ការផ្ទុកថាមពលបាន **550 MWh** ដែលបានដំឡើងត្រឹមថ្ងៃទី 15 ខែកុម្ភៈ ឆ្នាំ 2023

**បន្ទុកអគ្គិសនី**

ត្រឹមឆ្នាំ 2035 ទំនងជាមានការកើនឡើងដល់ 50% បើធៀបនឹងថ្ងៃនេះ (60 GWh ដល់ទំហំ 90+ GWh)

គោលដៅនៃការផ្ទុកថាមពលក្នុងទំហំ **1,000 MWh** ត្រឹមឆ្នាំ 2025

ទំហំផ្ទុក **5.8 GW** ត្រឹមឆ្នាំ 2050

# បញ្ហាប្រឈមជាមួយនឹងនីតិវិធីអនុញ្ញាតដែលមានស្រាប់

- ដំណើរការអនុញ្ញាតមានរយៈពេលយូរ មិនអាចទាយទុកជាមុនបាន និងជួនកាលមានលក្ខណៈស្រដៀងគ្នាដដែល
  - ពេលវេលាកំណត់មានភាពខុសគ្នាខ្លាំង ហើយគម្រោងមួយចំនួនបានចំណាយពេលរហូតដល់មួយទសវត្សរ៍ដើម្បីបញ្ចប់។
  - តាមប្រវត្តិពីដើមមក ក្រុមប្រឹក្សាភិបាលជ្រើសរើសទីតាំងគ្រឿងបរិក្ខារថាមពល (EFSB) បានចំណាយពេលចន្លោះពី 1 ដល់ 4 ឆ្នាំ ដើម្បីផ្តល់ការអនុញ្ញាតឱ្យដល់ការសាងសង់ បន្ទាប់ពីរយៈពេលនោះ គម្រោងនៅតែត្រូវការលិខិតអនុញ្ញាតក្នុងមូលដ្ឋានផ្សេងៗគ្នា និងពីរដ្ឋទាំងអស់។
- ឱកាសសម្រាប់បណ្តឹងឧទ្ធរណ៍លើលិខិតអនុញ្ញាតដាច់ដោយឡែកនីមួយៗអាចបណ្តាលឱ្យមានការពន្យារពេលជាច្រើនឆ្នាំ។
- សហគមន៍មានអារម្មណ៍ថា ជាញឹកញាប់ពួកគេមិនបានរួមចំណែកមតិយោបល់គ្រប់គ្រាន់ ឬប្រកបដោយឥទ្ធិពលនៅក្នុងការជ្រើសរើសទីតាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលៗនោះទេ។
- សហគមន៍អាចមិនមានធនធានចាំបាច់ដើម្បីចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការអនុញ្ញាតទេ។
- **រដ្ឋ Massachusetts នឹងមិនបំពេញតាមដែនកំណត់កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (GHG) របស់យើងដោយគ្មានការកែទម្រង់ទេ។**

# គណៈកម្មការទទួលបន្ទុកការជ្រើសរើសទីតាំង និងការអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធថាមពល

- គណៈកម្មការបានបង្កើតឡើងតាមបទបញ្ញាប្រតិបត្តិលេខ 620
- តម្រូវឱ្យផ្តល់ដំបូន្មានដល់អភិបាលលើ៖
  1. **ការពន្លឿនការដាក់អនុវត្តហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតប្រកបដោយទំនួលខុសត្រូវតាមរយៈការជ្រើសរើសទីតាំង និងអនុញ្ញាតឱ្យមានការកែទម្រង់ដោយអនុលោមតាមលក្ខខណ្ឌតម្រូវផ្លូវច្បាប់ជាធរមាន** និងផែនការថាមពលស្អាត និងអាកាសធាតុ។
  2. **ការសម្រួលសម្រួលឱ្យមានការរួមចំណែកមតិយោបល់ពីសហគមន៍** ទៅក្នុងការជ្រើសរើសទីតាំង និងការអនុញ្ញាតចំពោះហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត និង
  3. **ការធានា ថាអត្ថប្រយោជន៍ពីការប្រែប្រួលថាមពលស្អាតត្រូវបានចែករំលែកប្រកបដោយសមភាព**ក្នុងចំណោមអ្នករស់នៅក្នុង Commonwealth។
- គាំទ្រដោយក្រុមការងារអនុញ្ញាត និងជ្រើសរើសទីតាំងអន្តរទីភ្នាក់ងារ និងក្រុមប្រឹក្សាអ្នកជំនាញអនុវត្តការជ្រើសរើសទីតាំង។
- ការប្រជុំចំនួន 15 លើកបានធ្វើឡើងក្នុងរយៈពេលប្រាំបីខែ។
- វគ្គស្តាប់មតិសាធារណៈចំនួនពីរលើកបានធ្វើឡើង ហើយបានទទួលមតិសាធារណៈជាង 1,500 មតិ។
- អនុសាសន៍ដែលបានផ្ញើជូនអភិបាល Healey កាលពីថ្ងៃទី 29 ខែមីនា ឆ្នាំ 2024។

# បង្រួមការអនុញ្ញាតរបស់រដ្ឋ

- រាល់លិខិតអនុញ្ញាតក្នុងមូលដ្ឋាន តំបន់ និងរដ្ឋទាំងអស់ សម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតធំៗ ដែលត្រូវបានរួមបញ្ចូលទៅក្នុងលិខិតអនុញ្ញាតបង្រួមចូលគ្នាមួយ ដែលចេញដោយក្រុមប្រឹក្សាភិបាលជ្រើសរើសទីតាំងគ្រឿងបរិក្ខារថាមពល (EFSB)។
- រាល់ទីភ្នាក់ងាររដ្ឋ និងមូលដ្ឋានទាំងអស់ដែលនឹងមានតួនាទីផ្តល់ការអនុញ្ញាតផ្សេងទៀតអាចធ្វើអន្តរាគមន៍ និងចូលរួមដោយស្វ័យប្រវត្តិតាមរយៈការចេញសេចក្តីថ្លែងការណ៍អំពីលក្ខខណ្ឌអនុញ្ញាតដូចបានផ្តល់អនុសាសន៍។
- រាល់គម្រោងទាំងអស់ត្រូវតែដាក់បញ្ជូនការវិភាគផលប៉ះពាល់រួមដែលជាផ្នែកនៃការដាក់ពាក្យសុំទៅកាន់ EFSB។
- សេចក្តីសម្រេចលើលិខិតអនុញ្ញាតត្រូវតែចេញក្នុងរយៈពេលតិចជាង 15 ខែចាប់ពីការកំណត់ភាពពេញលេញនៃការដាក់ពាក្យសុំ។
- សេចក្តីសម្រេចរបស់ EFSB អាចត្រូវបានប្តឹងឧទ្ធរណ៍ដោយផ្ទាល់ទៅតុលាការកំពូលដែលមានដែនសមត្ថកិច្ច។



- អនុវត្តចំពោះគ្រឿងបរិក្ខារផលិតថាមពលទំហំ >25 MW គ្រឿងបរិក្ខារផ្ទុកថាមពលទំហំ >100 MWh ហេដ្ឋារចនាសម្ព័ន្ធទាក់ទងនឹងខ្យល់នៅឯនាយសមុទ្រ និងគម្រោងបញ្ជូនថាមពលថ្មីខ្នាតធំ

# បង្រួមការអនុញ្ញាតក្នុងតំបន់

- រដ្ឋាភិបាលក្នុងមូលដ្ឋាន (ក្រុង និងគណៈកម្មការប្រចាំតំបន់ដូចជាគណៈកម្មការរបស់ Cape Cod និង Martha's Vineyard ជាដើម) រក្សាអំណាចផ្តល់អនុញ្ញាតទាំងអស់សម្រាប់គម្រោងដែលមិនស្ថិតក្រោមការពិនិត្យដោយ EFSB។
- រដ្ឋាភិបាលក្នុងមូលដ្ឋានអាចបន្តដំណើរការដំណើរការអនុម័តដាច់ដោយឡែកក្នុងពេលដំណាលគ្នា (ឧទាហរណ៍ តំបន់ដីសើម ការកំណត់តំបន់ជាដើម)។
- រដ្ឋាភិបាលក្នុងមូលដ្ឋាននឹងត្រូវបានតម្រូវឱ្យចេញលិខិតអនុញ្ញាតតែមួយដែលរួមបញ្ចូលការអនុម័តផ្សេងៗសម្រាប់ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត។
- សេចក្តីសម្រេចលើលិខិតអនុញ្ញាតត្រូវតែចេញក្នុងរយៈពេល 12 ខែ។
- រដ្ឋាភិបាលក្នុងមូលដ្ឋានអាចបញ្ជូនការពិនិត្យវាយតម្លៃដើម្បីផ្តល់ការអនុញ្ញាតដោយផ្ទាល់ទៅកាន់ EFSB ប្រសិនបើពួកគេមិនមានធនធានគ្រប់គ្រាន់។
- ការដាក់ពាក្យសុំលិខិតអនុញ្ញាតក៏អាចត្រូវពិនិត្យវាយតម្លៃដោយ EFSB បន្ទាប់ពីសេចក្តីសម្រេចចុងក្រោយរបស់រដ្ឋាភិបាលក្នុងមូលដ្ឋាន ប្រសិនបើការពិនិត្យវាយតម្លៃត្រូវបានស្នើសុំដោយភាគីដែលអាចបង្ហាញថា ពួកគេទទួលរងផលប៉ះពាល់យ៉ាងខ្លាំង និងយ៉ាងជាក់លាក់ដោយការសម្រេចចិត្ត បន្ទាប់មកប្តឹងឧទ្ធរណ៍បន្ថែមទៀតដោយផ្ទាល់ទៅតុលាការកំពូលដែលមានដែនសមត្ថកិច្ច។
- នាយកដ្ឋានធនធានថាមពល (DOER) ទទួលខុសត្រូវក្នុងការបង្កើតពាក្យសុំលិខិតអនុញ្ញាតស្តង់ដារបស់ក្រុង និងបណ្តុំរួមនៃស្តង់ដាសុខភាព សុវត្ថិភាព និងបរិស្ថានកម្រិតមូលដ្ឋាន ដែលត្រូវប្រើដោយអ្នកធ្វើការសម្រេចចិត្តក្នុងមូលដ្ឋាននៅពេលអនុញ្ញាតឱ្យមានហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត។



- អនុវត្តចំពោះគ្រឿងបរិក្ខារផលិតថាមពលទំហំ <25 MW គ្រឿងបរិក្ខារផ្ទុកថាមពលទំហំ <100 MWh និងគម្រោងបញ្ជូនចរន្ត និងចែកចាយថាមពលដែលមិនមែនក្នុងដែនសមត្ថកិច្ចរបស់ EFSB

# ការចូលរួមពីសហគមន៍កាន់តែមានអត្ថន័យ និងយុត្តិធម៌

- ការបង្កើតការិយាល័យយុត្តិធម៌ និងសមធម៌ផ្នែកបរិស្ថានជាផ្លូវការទៅតាមលក្ខន្តិកៈដែលមានអាណត្តិដាក់លាក់ដើម្បីបង្កើតការណែនាំទាក់ទងនឹងកិច្ចព្រមព្រៀងអត្ថប្រយោជន៍សហគមន៍ និងការវិភាគផលប៉ះពាល់រួម។
- លក្ខខណ្ឌតម្រូវនៃការចូលរួមជាចាំបាច់របស់សហគមន៍ជាលើកដំបូង រួមបញ្ចូលទាំងការចងក្រងឯកសារអំពីកិច្ចខិតខំប្រឹងប្រែងដើម្បីចូលរួមជាមួយអង្គការក្នុងសហគមន៍ និងការបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតកិច្ចព្រមព្រៀងអត្ថប្រយោជន៍សហគមន៍។
- ផ្នែកការងារថ្មីសម្រាប់ការចូលរួមជាសាធារណៈនៅនាយកដ្ឋានសេវាសាធារណៈ (DPU) ដើម្បីជួយដល់សំណួរនានាអំពីការចូលរួម និងដំណើរការទៅតាមដំណើរការនីតិវិធីរបស់ DPU និង EFSB សម្រាប់សហគមន៍ និងអ្នកដាក់ពាក្យស្នើសុំគម្រោង។
- ផ្នែកថ្មីខាងជ្រើសរើសទីតាំង និងផ្តល់ការអនុញ្ញាតនៅនាយកដ្ឋាន DOER ដើម្បីជួយដល់សំណួរនានាអំពីការចូលរួម និងដំណើរការក្នុងការផ្តល់ការអនុញ្ញាតក្នុងមូលដ្ឋានសម្រាប់សហគមន៍ និងអ្នកដាក់ពាក្យស្នើសុំគម្រោង។
- ជំនួយហិរញ្ញវត្ថុរបស់អន្តរការីមានសម្រាប់អង្គភាពដែលខ្វះខាតធនធាន ដែលចង់ចូលរួមក្នុងដំណើរការនីតិវិធីរបស់ EFSB ហើយត្រូវបានផ្តល់ឋានៈជាអន្តរការី។
- ក្រុងដែលមានប្រជាជនចំនួន 7,500 នាក់ ឬតិចជាងនេះមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុដោយស្វ័យប្រវត្តិ។

# សេចក្តីសង្ខេបអំពីដំណើរការកំណែទម្រង់




ដំណើរការបច្ចុប្បន្នមានភាពច្របូកច្របល់ ហើយពន្យារពេលដល់ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតដែលត្រូវការយ៉ាងចាំបាច់អស់រយៈពេលមួយទសវត្សរ៍។




អាជ្ញាធរមានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតក្នុងរដ្ឋ និងមូលដ្ឋាននៅតែមានលក្ខណៈដដែលភាគច្រើន ប៉ុន្តែការកំណត់ពេលត្រូវបានបង្រួញឱ្យខ្លី។

* គម្រោងសេវាសាធារណៈតូចៗ ដូចជាការពង្រីកការបញ្ជូនថាមពលទំហំតូចអាចជ្រើសរើសចូលរួមក្នុងដំណើរការនៃការអនុញ្ញាតរបស់ EFSB។

# កំណែទម្រង់បន្ថែម

- ផ្នែកកិច្ចការថាមពល និងបរិស្ថាន (EEA) តម្រូវឱ្យបង្កើតវិធីសាស្ត្រ និងការណែនាំអំពីភាពសមស្របនៃទីតាំង ដើម្បីជូនដំណឹងដល់ដំណើរការនៃការអនុញ្ញាតរបស់រដ្ឋ និងមូលដ្ឋានអំពីភាពសមស្របនៃទីតាំងសម្រាប់ការអភិវឌ្ឍថាមពលស្អាត និងជួយអ្នកអភិវឌ្ឍន៍ដើម្បីបញ្ចៀស កាត់បន្ថយ និងបន្ធូរបន្ថយផលប៉ះពាល់បរិស្ថាន។
- កៅអីថ្មីចំនួនប្រាំនៅក្នុង EFSB៖
  - ស្នងការនាយកដ្ឋានជលផល និងរុក្ខាប្រមាញ់
  - ស្នងការនាយកដ្ឋានសុខភាពសាធារណៈ
  - អ្នកតំណាងនៃសមាគមក្រុងក្នុងរដ្ឋ Massachusetts
  - អ្នកតំណាងនៃសមាគមក្នុងរដ្ឋ Massachusetts របស់សមាគមរៀបចំផែនការប្រចាំតំបន់ និង
  - អ្នកតំណាងដែលមានជំនាញខាងយុត្តិធម៌លើផ្នែកបរិស្ថាន និង/ឬអធិបតេយ្យភាពជនជាតិដើមភាគតិច។
- ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតនៅក្រោមយុត្តាធិការរបស់ EFSB ត្រូវបានលើកលែងចេញពីការពិនិត្យដោយច្បាប់ស្តីពីគោលនយោបាយបរិស្ថានក្នុងរដ្ឋ Massachusetts (MEPA)។
- អាជ្ញាធរមានសមត្ថកិច្ចក្នុងការជ្រើសរើសទីតាំង DPU ពីដើមមក (ឧទាហរណ៍ ការអនុញ្ញាតឱ្យកំណត់តំបន់ទូទៅ និងសិទ្ធិយកដីមកប្រើសម្រាប់ការបញ្ជូនថាមពល និងលូបង្ហូរទឹក) ត្រូវបានផ្ទេរទៅឱ្យ EFSB។

# តួនាទី និងទំនួលខុសត្រូវ

- មានចរន្តការងារចំនួនប្រាំដែលកើតចេញច្បាប់ ដែលកំពុងអនុវត្តដោយទីភ្នាក់ងារបីផ្សេងគ្នាគឺ EEA, DPU និង DOER
- ភាគច្រើននៃចរន្តការងារទាំងនេះទាក់ទងគ្នាតាមរបៀបមួយចំនួន ប៉ុន្តែទីភ្នាក់ងារនីមួយៗបម្រើគោលបំណងដាច់ដោយឡែកពីគ្នា ហើយបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់ជាក់លាក់
- ទីភ្នាក់ងារទាំងបីមានការប្រាស្រ័យទាក់ទងយ៉ាងជិតស្និទ្ធជាមួយគ្នា
- ទីភ្នាក់ងាររដ្ឋផ្សេងទៀតដែលមានតួនាទីក្នុងការអនុញ្ញាតខាងថាមពលសំខាន់ៗក៏ទទួលបានការពិគ្រោះយោបល់ផងដែរ ខណៈដែលសំណើត្រូវបានបង្កើតឡើង

**ចរន្តការងារ**

- ការណែនាំអំពីភាពសមស្រប នៃទីតាំង — *EEA*
- ផលប៉ះពាល់រួម និងការណែនាំអំពីអត្ថប្រយោជន៍សហគមន៍ — *EEA*
- វិធាននៃការជ្រើសរើសទីតាំង និងការអនុញ្ញាតសម្រាប់ក្រុង — *DOER*
- វិធាននៃការជ្រើសរើសទីតាំង និងការអនុញ្ញាតរបស់ EFSB — *EFSB*
- ច្បាប់ស្តីពីជំនួយមូលនិធិសម្រាប់អន្តរការីនៃ DPU — *DPU*

# ជំហានបន្ទាប់

- បទប្បញ្ញត្តិនេះត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី 1 ខែ មីនា ឆ្នាំ 2026។
  - ថវិកា FY25 បន្ថែមរបស់អភិបាលរដ្ឋដែលបានដាក់នៅថ្ងៃទី 2 ខែមេសាស្នើឱ្យពន្យារកាលកំណត់នេះរហូតដល់ថ្ងៃទី 1 ខែឧសភា ឆ្នាំ 2026។
- EEA, DPU និង EFSB កំពុងបង្កើតផែនការអនុវត្តសម្រាប់ប្រធានបទដាច់ដោយឡែក ហើយបានកំណត់ពេលប្រជុំភាគីពាក់ព័ន្ធចំនួនបួនសម្រាប់ខែមេសា និងខែឧសភា។
- DOER និង DPU កំពុងរើសបុគ្គលិកថ្មី។
- ព័ត៌មានបន្ថែមអំពីដំណើរការអាចរកបាននៅលើគេហទំព័រ៖ www.mass.gov/energypermitting
- អាចបញ្ជូនសំណួរទៅអាសយដ្ឋានអ៊ីមែល energypermitting@mass.gov

# បេសកកម្មរបស់យើង

## បេសកកម្មរបស់នាយកដ្ឋានធនធានថាមពល (DOER) គឺដើម្បីបង្កើតអនាគតប្រកបដោយថាមពលស្អាត មានតម្លៃសមរម្យ មានភាពធន់ និងគ្រប់គ្រាន់សម្រាប់មនុស្សគ្រប់រូបនៅក្នុង Commonwealth។

**យើងជានរណា៖** ក្នុងនាមជាការិយាល័យថាមពលរដ្ឋ DOER គឺជាទីភ្នាក់ងារគោលនយោបាយថាមពលជាមូលដ្ឋានសម្រាប់ Commonwealth។ DOER គាំទ្រគោលដៅថាមពលស្អាតរបស់ Commonwealth ជាផ្នែកមួយនៃការឆ្លើយតបគ្រប់ជ្រុងជ្រោយទៅនឹងការគំរាមកំហែងពីការផ្លាស់ប្តូរអាកាសធាតុ។ DOER ផ្តោតលើការផ្លាស់ប្តូរថាមពលរបស់យើងដែលផ្គត់ផ្គង់ដោយមានការបំពុលបរិស្ថាន និងការចំណាយតិចតួច ការកាត់បន្ថយ និងកែច្នៃតម្រូវការថាមពល និងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធថាមពលរបស់យើង។

**អ្វីដែលយើងធ្វើ៖** ដើម្បីបំពេញតាមគោលដៅរបស់យើង DOER បានតភ្ជាប់ និងសហការជាមួយភាគីពាក់ព័ន្ធក្នុងវិស័យថាមពលដើម្បីបង្កើតគោលនយោបាយប្រកបដោយប្រសិទ្ធភាព។ DOER អនុវត្តគោលនយោបាយនេះតាមរយៈការធ្វើផែនការ បទប្បញ្ញត្តិ និងការផ្តល់មូលនិធិ។ DOER ផ្តល់ឧបករណ៍ដល់បុគ្គល អង្គការ និងសហគមន៍ដើម្បីគាំទ្រគោលដៅថាមពលស្អាតរបស់ពួកគេ។ DOER បានប្តេជ្ញាចិត្តចំពោះតម្លាភាព និងការអប់រំ ដោយគាំទ្រការទទួលបានព័ត៌មាន និងចំណេះដឹងអំពីថាមពល។



**យើងជាទីភ្នាក់ងារ**

ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពល និងបរិស្ថាន (EEA)។

# ទំនួលខុសត្រូវក្នុងការអនុញ្ញាត និងការកំណត់ទីតាំងគ្រឿងបរិក្ខារថាមពលស្អាត

## ច្បាប់អាកាសធាតុឆ្នាំ 2024 នៅផ្នែកស្តីពីការកំណត់ទីតាំង និងការអនុញ្ញាតបានបង្រួបបង្រួមការពិនិត្យវាយតម្លៃ និងដំណើរការអនុម័តការអនុញ្ញាតនៅកម្រិតរដ្ឋ និងក្នុងតំបន់



### គម្រោងខ្នាតធំ - ក្រុមប្រឹក្សាភិបាលជ្រើសរើសទីតាំងគ្រឿងបរិក្ខារថាមពល (EFSB)

- **លិខិតអនុញ្ញាតតែមួយរួមគ្នា**ពី ESFB ជំនួសឱ្យលិខិតអនុញ្ញាតពីរដ្ឋ តំបន់ និងកម្រិតមូលដ្ឋានជាច្រើន
- សេចក្តីសម្រេច**ក្នុងរយៈពេល 15 ខែ**



### គម្រោងខ្នាតតូច - សាលាក្រុង

- **លិខិតអនុញ្ញាតតែមួយរួមគ្នាពីអង្គភាពសាលាក្រុង** ជំនួសឱ្យលិខិតអនុញ្ញាតកម្រិតមូលដ្ឋានជាច្រើន
- សេចក្តីសម្រេច**ក្នុងរយៈពេល 12 ខែ**

# តួនាទីរបស់ DOER

**ច្បាប់នេះបានបង្កើតតួនាទីថ្មី – និងផ្នែកការងារថ្មី – សម្រាប់នាយកដ្ឋាន DOER ដើម្បីគាំទ្រដំណើរការកំណត់ទីតាំងគ្រឿងបរិក្ខារថាមពលក្នុងតំបន់ និងការអនុញ្ញាតឱ្យមានហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតតូចៗ។**

នាយកដ្ឋានកំណត់ទីតាំងគ្រឿងបរិក្ខារថាមពល និងអនុញ្ញាតថាមពលស្អាតនឹងបង្កើតបទប្បញ្ញត្តិ និងផ្តល់ការគាំទ្របច្ចេកទេស និងជំនួយដល់ក្រុង អ្នកស្នើគម្រោង និងភាគីពាក់ព័ន្ធផ្សេងទៀត។

នៅក្នុងបទប្បញ្ញត្តិ DOER តម្រូវឱ្យកំណត់៖

- ស្តង់ដាសុខភាពសាធារណៈ សុវត្ថិភាព និងបរិស្ថាន
- ការដាក់ពាក្យស្នើសុំស្តង់ដាទូទៅ
- លក្ខខណ្ឌតម្រូវនៃការដាក់ឯកសារជាមុន
- ស្តង់ដាសម្រាប់ការអនុវត្តការណែនាំអំពីភាពសមស្របនៃទីតាំង
- លិខិតអនុញ្ញាតបង្រួបបង្រួម
- ***ការណែនាំសម្រាប់នីតិវិធី/ ពេលវេលាកំណត់***
- គូភាគីទទួលខុសត្រូវចំពោះការអនុវត្ត
- ដំណើរការសម្រាប់ថ្លៃសេវាក្រុងចំពោះការកាត់បន្ថយសំណងបរិស្ថាន (មិនតម្រូវទេ)
- ***វិធាន និងលក្ខខណ្ឌតម្រូវទូទៅ***

# បន្ទាត់ពេលវេលាឆ្នាំ 2025

ការកំណត់ទីតាំងគ្រឿងបរិក្ខារថាមពល និងការអនុញ្ញាតរបស់ DOER នៅឆ្នាំ 2025 នឹងមានបីដំណាក់កាលៈ

## 01

### ការកំណត់ផ្នែកការងារថ្មី

**រដូវរងា-រដូវក្តៅៈ**
ការជ្រើសរើសបុគ្គលិកថ្មី និងការណែនាំអំពីទំនួលខុសត្រូវ

## 02

### ការចូលរួមពីភាគីពាក់ព័ន្ធ

**និទាឃរដូវ -រដូវក្តៅៈ**
ខាងក្នុង និងខាងក្រៅ
កំណត់គោលដៅឱ្យបានទូលំទូលាយជាងមុន

## 03

### សេចក្តីព្រាងចំពោះបទប្បញ្ញត្តិនានា

**ចុងរដូវក្តៅ/រដូវស្លឹកឈើជ្រុះៈ**
បោះពុម្ពផ្សាយសេចក្តីព្រាងបទប្បញ្ញត្តិ
*(បទប្បញ្ញត្តិចុងក្រោយដល់កាលកំណត់ត្រឹមថ្ងៃទី1 ខែ មីនា ឆ្នាំ 2026)*

# ទាក់ទងមកយើងខ្ញុំ

100 Cambridge St. - 9th Floor - Boston, MA 02114

doer.siting.permitting@mass.gov

((617) 626-7300

x.com/massdoer

bsky.app/profile/massdoer.bsky.social

www.mass.gov/orgs/massachusetts-department-of-energy-resources

## យើងទន្ទឹងរង់ចាំទទួលបានព័ត៌មាន
## ពីអ្នក។



# ពង្រាងសំណើអំពីបទប្បញ្ញត្តិនៃនីតិវិធី

- តើក្រុមប្រឹក្សាភិបាលកំណត់ទីតាំងគ្រឿងបរិក្ខារថាមពល (ក្រុមប្រឹក្សាភិបាលកំណត់ទីតាំង ឬ EFSB) ជាអ្វី?
- តើច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024 មានការផ្លាស់ប្តូរអ្វីខ្លះចំពោះការកំណត់ទីតាំង និងអនុញ្ញាត?
  - ការផ្លាស់ប្តូរចំពោះក្រុមប្រឹក្សាកំណត់ទីតាំង និងរបៀបដែលក្រុមប្រឹក្សានោះធ្វើការសេចក្តីសម្រេច
  - ការផ្លាស់ប្តូរចំពោះយុត្តាធិការរបស់ក្រុមប្រឹក្សាកំណត់ទីតាំង
  - ការផ្លាស់ប្តូរចំពោះដំណើរការរបស់ក្រុមប្រឹក្សាកំណត់ទីតាំង
  - បន្ថែមប្រភេទនៃដំណើរការថ្មី
- បទប្បញ្ញត្តិនៃនីតិវិធីនឹងយោង និងបញ្ចូលបទប្បញ្ញត្តិ និងការណែនាំផ្សេងទៀត
- សំណើសុំមតិយោបល់

# តើក្រុមប្រឹក្សាភិបាលកំណត់ទីតាំងគ្រឿងបរិក្ខារថាមពលជាអ្វី?

- ក្រុមប្រឹក្សាឯករាជ្យមួយ ត្រូវបានបង្កើតឡើងប្រហែល 50 ឆ្នាំមុន (ជា EFSC)
- មានសមាជិកចំនួនប្រាំបួននាក់៖ សមាជិកដែលមានមុខដំណែងចំនួនប្រាំមួយនាក់ និងសមាជិកសាធារណៈចំនួនបីនាក់ ដែលដឹកនាំដោយរដ្ឋលេខាធិការក្រសួងថាមពល និងបរិស្ថាន។
  - យុត្តាធិការរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងគឺនៅលើកន្លែងផលិតថាមពលធំ – កន្លែងផលិតថាមពលទាំងនេះត្រូវបានកំណត់ដោយលក្ខន្តិកៈ៖
    - ការបង្កើតកន្លែងផលិតថាមពលស្មើ ឬច្រើនជាង 100 MW និងរចនាសម្ព័ន្ធបន្ថែម (កម្រិតកំណត់នេះត្រូវបានកាត់បន្ថយដល់ 25 MW នៅក្នុងច្បាប់ស្តីពីអាកាសធាតុឆ្នាំ 2024)
    - បណ្ដាញបញ្ជូនចរន្តអគ្គិសនី
      - ច្រករបៀងថ្មីស្មើ ឬច្រើនជាងបណ្ដាញ 69 kV និងស្មើ ឬច្រើនជាងប្រវែង 1 ម៉ាយល៍
      - ច្រករបៀងដែលមានស្រាប់ស្មើ ឬច្រើនជាងបណ្ដាញ 115 kV និងប្រវែងជាង 10 ម៉ាយល៍ លើកលែងតែការបញ្ជូនឡើងវិញ ឬការសាងសង់ឡើងវិញក្នុងតង់ស្យុងដូចគ្នា
    - បណ្ដាញទុយយោផ្ទេរឧស្ម័ននៅក្នុងរដ្ឋលើសពី 100 psig និងប្រវែងជាងមួយម៉ាយល៍ លើកលែងតែការសាងសង់ឡើងវិញ ឬការតម្លើងទុយយោបង្ហូរឧស្ម័នដែលមានស្រាប់
    - កន្លែងផ្ទុក/ទុយយោបង្ហូរប្រេងដែលមានប្រវែងជាង 1 ម៉ាយល៍ ធុងផ្ទុកថ្មីជាង 500,000 បារ៉ែល
    - កន្លែងផ្ទុកឧស្ម័ន (ឧស្ម័នធម្មជាតិរាវ (LNG) ឬឧស្ម័នធម្មជាតិដែលបានបង្ហាប់ (CNG)) លើសពី 25,000 ហ្គាឡុង
- ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងរៀបចំដំណើរការនីតិវិធីវិនិច្ឆ័យ ចេញសេចក្តីសម្រេចលើការដាក់ញត្តិដើម្បីសាងសង់ និងបញ្ជាក់ពីផលប៉ះពាល់បរិស្ថាន និងផលប្រយោជន៍សាធារណៈ សម្រាប់បរិក្ខារនៅក្រោមយុត្តាធិការ។
- អាចដាក់បណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងដោយផ្ទាល់ទៅតុលាការកំពូលដែលមានដែនសមត្ថកិច្ចនៅរដ្ឋ Massachusetts។

# បទប្បញ្ញត្តិស្តីពីការកំណត់ទីតាំង និងការអនុញ្ញាតសំខាន់ៗនៃច្បាប់អាកាសធាតុឆ្នាំ 2024

- ពង្រីកក្រុមប្រឹក្សាកំណត់ទីតាំងពីសមាជិកចំនួនប្រាំបួនទៅដប់មួយនាក់ ដោយបង្កើតអាណត្តិថ្មីវិសាលភាពនៃការពិនិត្យវាយតម្លៃ និងលទ្ធផលដែលតម្រូវឱ្យមាន។
- បង្កើតប្រភេទហេដ្ឋារចនាសម្ព័ន្ធថ្មី៖ ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត (CEIF)។
- បង្កើតកម្មវិធីអនុញ្ញាតដែលបង្រួបបង្រួមកម្មវិធីទាំងពីរ។
  - ការអនុញ្ញាតរួមគឺជាការអនុញ្ញាតមួយដែលរួមបញ្ចូលទាំងការអនុញ្ញាតរបស់រដ្ឋ តំបន់ និងមូលដ្ឋានទាំងអស់ ដែលនឹងត្រូវការដើម្បីសាងសង់ និងដំណើរការហេដ្ឋារចនាសម្ព័ន្ធ CEIF។ និយមន័យនេះមិនរាប់បញ្ចូលការអនុញ្ញាតសហព័ន្ធមួយចំនួននោះទេ។
    - ហេដ្ឋារចនាសម្ព័ន្ធ CEIF ខ្នាតធំ - ការអនុញ្ញាតរួមដែលត្រូវផ្តល់ដោយក្រុមប្រឹក្សាកំណត់ទីតាំង។
    - ហេដ្ឋារចនាសម្ព័ន្ធ CEIF ខ្នាតតូច - ការអនុញ្ញាតរួមក្នុងតំបន់ដែលត្រូវផ្តល់ដោយក្រុង។
- ផ្តល់កាលបរិច្ឆេទកំណត់សម្រាប់ការពិនិត្យវាយតម្លៃហេដ្ឋារចនាសម្ព័ន CEIF និងការអនុម័តលើការសាងសង់ ប្រសិនបើកាលបរិច្ឆេទកំណត់មិនត្រូវបានបំពេញតាមទេនោះ។
- បង្កើតលក្ខខណ្ឌតម្រូវថ្មីៗសម្រាប់អ្នកដាក់ពាក្យស្នើសុំហេដ្ឋារចនាសម្ព័ន្ធ CEIF រួមមាន៖
  - ការប្រឹក្សាយោបល់ និងការចូលរួមមុនការដាក់ឯកសារស្នើសុំ។
  - ការវាយតម្លៃផលប៉ះពាល់សរុប (CIA) (តម្រូវឱ្យមានផងដែរសម្រាប់ការវាយតម្លៃដែលមិនមែនជាហេដ្ឋារចនាសម្ព័ន្ធ CEIF)។
- ប្តូរយុត្តាធិការកំណត់ទីតាំងរបស់នាយកដ្ឋានប្រើប្រាស់សេវាសាធារណៈមួយចំនួនទៅក្រុមប្រឹក្សាកំណត់ទីតាំងដោយមានការបង្រួបបង្រួមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាកំណត់ទីតាំង។

# លក្ខខណ្ឌតម្រូវថ្មីសម្រាប់ក្រុមប្រឹក្សាកំណត់ទីតាំង 980 CMR 2.00

- ពិនិត្យមើលសមាជិកភាពនៃក្រុមប្រឹក្សាកំណត់ទីតាំង។ G.L. c. 164, § 69H។
  - បន្ថែមមុខតំណែងថ្មីចំនួនពីរ – នាយកដ្ឋាននេសាទ និងរុក្ខាប្រមាញ់ និងក្រសួងសុខភាពសាធារណៈ (និងកាត់បន្ថយទំហំនាយកដ្ឋានសេវាប្រើប្រាស់សាធារណៈទៅមួយអាសនៈ)
  - បង្កើនអាសនៈសម្រាប់សមាជិកសាធារណៈពីបីទៅបួនអាសនៈ៖ សមាគមទីភ្នាក់ងាររៀបចំផែនការក្នុងតំបន់ រដ្ឋ Mass សមាគមក្រុងនៃរដ្ឋ រដ្ឋ Mass យុត្តិធម៌បរិស្ថាន/អធិបតេយ្យភាពជនជាតិដើមភាគតិច និងកម្លាំងពលកម្ម (និងលុបចោលសមាជិកសាធារណៈដែលតំណាងឱ្យថាមពល និងបរិស្ថាន)។
- ពង្រីកយុត្តាធិការរបស់ក្រុមប្រឹក្សាកំណត់ទីតាំង។ ឧទាហរណ៍ បន្ថែមយុត្តាធិការលើប្រព័ន្ធផ្ទុកថាមពលថ្ម។
- បង្កើតប្រភេទថ្មី និងច្បាប់វិធានថ្មីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ CEIF។
- បង្កើតដំណើរការថ្មីសម្រាប់ក្រុមប្រឹក្សាកំណត់ទីតាំងដើម្បីចេញលិខិតអនុញ្ញាតរួម។

# លក្ខខណ្ឌតម្រូវថ្មីៗសម្រាប់ក្រុមប្រឹក្សាកំណត់ទីតាំង (ត)

- កំណត់អាណត្តិផ្លូវច្បាប់ថ្មី និងវិសាលភាពនៃការពិនិត្យវាយតម្លៃសម្រាប់ក្រុមប្រឹក្សាកំណត់ទីតាំង។
  - ក្រុមប្រឹក្សាកំណត់ទីតាំងកំពុងតែកំណត់ថា តើគម្រោងមួយនឹងផ្តល់នូវការផ្គត់ផ្គង់ថាមពលដែលអាចជឿជាក់បានដោយមានផលប៉ះពាល់ដល់បរិស្ថានជាអប្បបរមានិងមានតម្លៃតិចបំផុតដែរឬទេ។
  - ស្ថិតក្រោមច្បាប់អាកាសធាតុឆ្នាំ 2024 នៅពេលពិនិត្យមើលគម្រោងដែលបានស្នើឡើង ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងត្រូវពិចារណាលើចំណុចនានាដោយរួមបញ្ចូល បន្ទុកប្រមូលផ្តុំលើសហគមន៍ដែលជាម្ចាស់ផ្ទះ ផលប៉ះពាល់សុខភាពសាធារណៈ និងផលប៉ះពាល់លើការប្រែប្រួលអាកាសធាតុ។ ច្បាប់នេះក៏រួមមានបញ្ជីនៃការរកឃើញដែលក្រុមប្រឹក្សាកំណត់ទីតាំងត្រូវធ្វើសេចក្តីសម្រេចរបស់ខ្លួនលើគម្រោងដែលបានស្នើឡើងផងដែរ។
- បន្ថែមកាលបរិច្ឆេទកំណត់តាមច្បាប់សម្រាប់ការពិនិត្យវាយតម្លៃរបស់ក្រុមប្រឹក្សាកំណត់ទីតាំងនៅលើហេដ្ឋារចនាសម្ព័ន្ធ CEIF ដែលបានស្នើឡើង។
  - ប្រសិនបើក្រុមប្រឹក្សាកំណត់ទីតាំងមិនចេញសេចក្តីសម្រេចត្រឹមថ្ងៃកំណត់ដែលបានតម្រូវ (មិនលើសពីរយៈពេល 15 ខែ) ទេ នោះគម្រោងនឹងត្រូវបានអនុម័តលើការសាងសង់ ហើយការអនុញ្ញាតជារួមរបស់ខ្លួននឹងត្រូវបានចេញដោយមានលក្ខខណ្ឌស្តង់ដា។
- បទប្បញ្ញត្តិបន្ថែម
  - ការបង្កើតផ្ទាំងគ្រប់គ្រង
  - ក្រុមប្រឹក្សាកំណត់ទីតាំងដើម្បីជួបប្រជុំនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាកំណត់ទីតាំងសាធារណៈលក្ខណៈហាយប្រ៊ីដ

# បរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត

| ប្រភេទ/ការពិពណ៌នាអំពីបរិក្ខារ | សមត្ថភាព/ទំហំ | សិទ្ធអំណាចនៃការអនុញ្ញាត |
|---|---|---|
| **<u>ការបង្កើតថាមពល</u>** – ពន្លឺព្រះអាទិត្យ ខ្យល់ ដំណើរការរំលាយជាតិសរីរាង្គដោយគ្មានអុកស៊ីសែន | ≥ 25 MW (**ធំ**) | EFSB – ដំណើរការនៃការអនុញ្ញាតរួមរបស់រដ្ឋ និងក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាម § 69T |
| | <25 MW (**តូច**) | ក្នុងមូលដ្ឋាន - ដំណើរការនៃការអនុញ្ញាតរួមក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនក្នុង ស្របតាមច្បាប់ជំពូក 25A, § 21 [1]<br>EFSB – ការអនុញ្ញាតជារួមរបស់រដ្ឋស្របតាមច្បាប់ § 69V (EFSB ដែលអ្នកអភិវឌ្ឍជ្រើសចូលរួម) បើមិនដូច្នេះទេ ត្រូវមានការអនុញ្ញាតរបស់រដ្ឋនីមួយៗ |
| **<u>ប្រព័ន្ធផ្ទុកថាមពល</u>** | ≥100 MWh (**ធំ**) | EFSB – ការអនុញ្ញាតជារួមរបស់រដ្ឋ និងក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាមច្បាប់ § 69T |
| | <100 MWh (**តូច**) | ក្នុងមូលដ្ឋាន - ដំណើរការនៃការអនុញ្ញាតរួមក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនក្នុង ស្របតាមច្បាប់ជំពូក 25A, § 21 [1]<br>EFSB – ការអនុញ្ញាតរួមរបស់រដ្ឋស្របតាមច្បាប់ § 69V (EFSB ដែលអ្នកអភិវឌ្ឍជ្រើសរើសចូលរួម) មិនដូច្នោះទេ ត្រូវមានការអនុញ្ញាតរបស់រដ្ឋនីមួយៗផ្សេងពីគ្នា |
| **<u>ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនថាមពល</u>** (និងបរិក្ខារជំនួយ) - **ធំ**<br>- ≥69 kV <u>និង</u> ≥ 1 ម៉ាយល៍ (ច្រករបៀងថ្មី)<br>- ≥115 kV <u>និង</u> ≥10 ម៉ាយល៍ (ច្រករបៀងដែលមានស្រាប់) (លើកលែងតែការបញ្ជូនឡើងវិញក្នុងតង់ស្យុងដូចគ្នា)<br>- ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនថាមពលថ្មី (រួមទាំងស្ថានីយរង/រចនាសម្ព័ន្ធ) ដែលតម្រូវឱ្យមានការលើកលែងពីការកំណត់តំបន់<br>- កន្លែងដែលត្រូវការដើម្បីភ្ជាប់កង្ហារខ្យល់ទៅបណ្ដាញចែកចាយអគ្គិសនី → | | EFSB – ដំណើរការនៃការអនុញ្ញាតរួមរបស់រដ្ឋ និងក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាម § 69T<br><br>ការលើកលែងពីការកំណត់តំបន់របស់ EFSB ក៏ត្រូវបានទាមទារផងដែរ |
| **<u>ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនថាមពល</u>** (និងបរិក្ខារជំនួយ) - **ខ្នាតតូច**<br>- <1 ម៉ាយល៍ (ច្រករបៀងថ្មី)<br>- <10 ម៉ាយល៍ (ច្រករបៀងដែលមានស្រាប់)<br>- គម្រោងកម្រិតចែកចាយដែលបំពេញតាមដែនកម្រិតកំណត់នៃទំហំដែលនឹងត្រូវកំណត់ពេលក្រោយដោយនាយកដ្ឋាន DOER<br>- ការបញ្ជូនថាមពលបន្ត/ការសាងសង់ឡើងវិញក្នុងកម្រិតតង់ស្យុងដូចគ្នា<br>- ស្ថានីយរង/ការដំឡើងកម្រិតដែល<u>មិន</u>តម្រូវឱ្យមានការលើកលែងការកំណត់តំបន់ | | ក្នុងមូលដ្ឋាន - ដំណើរការនៃការអនុញ្ញាតរួមក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាមច្បាប់ជំពូកទី 25A, § 21<br><br>- **ឬ** -<br><br>EFSB – ដំណើរការនៃការអនុញ្ញាតរួមរបស់រដ្ឋ និងក្នុងមូលដ្ឋាន និងការដាក់ឯកសារជាមុនស្របតាមច្បាប់ § 69U (EFSB ដែលអ្នកអភិវឌ្ឍជ្រើសរើសចូលរួម) |

1. ដំណើរការដាក់ឯកសារជាមុននឹងធ្វើឡើងជាលើកដំបូងស្ថិតក្រោមគោលការណ៍ណែនាំអំពីការអនុញ្ញាតរួមក្នុងមូលដ្ឋានរបស់នាយកដ្ឋាន DOER ហើយនឹងមិនត្រូវស្ថិតក្រោមដំណើរការដាក់ឯកសារជាមុនរបស់ EFSB នោះទេ។ រដ្ឋាភិបាលក្នុងមូលដ្ឋានអាចផ្ទេរពាក្យសុំការអនុញ្ញាតរួមក្នុងតំបន់ទៅនាយករបស់ EFSB ប្រសិនបើធនធាន និងចំនួនបុគ្គលិកមិនអនុញ្ញាតឱ្យមានការត្រួតពិនិត្យក្នុងមូលដ្ឋានស្របតាមច្បាប់ § 69W ទេនោះ។ សំណើសុំសម្រាប់ការវិនិច្ឆ័យពីសេចក្ដីសម្រេចការអនុញ្ញាតរួមក្នុងមូលដ្ឋានថ្មីក៏អាចត្រូវបានដាក់ជូនទៅនាយក EFSB ស្របតាមច្បាប់ § 69W ហើយនឹងមិនតម្រូវឱ្យមានដំណើរការដាក់ឯកសារជាមុនបន្ថែមឡើយ។

ពណ៌គន្លឹះ៖ ទំនួលខុសត្រូវរបស់ EFSB ទំនួលខុសត្រូវរបស់នាយកដ្ឋាន DOER ដើម្បីបង្កើតស្តង់ដា

# ការផ្លាស់ប្តូរចំពោះរបៀបដែលក្រុមប្រឹក្សាកំណត់ទីតាំងអនុវត្តដំណើរការរបស់ខ្លួន

- ដំណើរការរបស់ក្រុមប្រឹក្សាកំណត់ទីតាំង៖
  - គឺជាដំណើរការវិនិច្ឆ័យ។ ដំណើរការត្រូវតែស្របតាមច្បាប់នៃនីតិវិធីរបស់រដ្ឋបាលរដ្ឋ Massachusetts - បទប្បញ្ញត្តិនៃនីតិវិធីរបស់ EFSB ឆ្លុះបញ្ចាំងពីតម្រូវការទាំងនេះ
  - ត្រូវតែមានការផ្តល់ជូននូវការដំណឹង
  - អនុញ្ញាតឱ្យមានការអន្តរាគមន៍
  - សេចក្តីសម្រេចត្រូវតែផ្អែកលើកំណត់ត្រានៃដំណើរការនីតិវិធី
  - សេចក្តីសម្រេចត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ
  - អាចប្តឹងឧទ្ធរណ៍សេចក្តីសម្រេចចុងក្រោយទៅតុលាការកំពូលបាន
- ការផ្លាស់ប្តូរ
  - កែនីតិវិធីដែលមានស្រាប់ឡើងវិញ
  - បង្កើតនីតិវិធីថ្មីៗ

# បទប្បញ្ញត្តិនៃនីតិវិធី
# 980 CMR 1.00

- <u>សេចក្តីជូនដំណឹង</u> – EFSB តម្រូវឱ្យផ្តល់ការជូនដំណឹងអំពីសវនាការមតិយោបល់សាធារណៈរបស់ខ្លួន
  - ច្បាប់ស្តីពីការជូនដំណឹងតាមប្រៃសណីយ៍ត្រូវបានកំណត់
    - ដល់អ្នករស់នៅក្នុងក្រុង (រួមទាំងម្ចាស់អចលនទ្រព្យ និងអ្នកជួល) និងអាជីវកម្មនៅក្នុងតំបន់នៃគម្រោង (ចម្ងាយផ្អែកលើប្រភេទគម្រោង)
    - ច្បាប់ពិសេសសម្រាប់ការលើកលែងតំបន់ – សេចក្តីជូនដំណឹងបន្ថែមដល់ក្រុមប្រឹក្សារៀបចំផែនការជុំវិញក្រុង
  - ផ្ញើអ៊ីមែលជូនដំណឹងដល់មន្ត្រីក្រុង
    - ចៅហ្វាយក្រុង និងក្រុមប្រឹក្សាក្រុង ឬក្រុមប្រឹក្សាជាប់ឆ្នោត និងរដ្ឋបាលក្រុង ក្រុមប្រឹក្សាកំណត់តំបន់បណ្តឹងឧទ្ធរណ៍ នាយកដ្ឋានការងារសាធារណៈ គណៈកម្មការអភិរក្ស
  - សេចក្តីជូនដំណឹងតាមកាសែត
  - ការបង្ហោះតាមគេហទំព័រ៖ EFSB អ្នកដាក់ពាក្យស្នើសុំ ស្នើសុំឱ្យក្រុងបង្ហោះសេចក្តីជូនដំណឹង
  - បិទបង្ហាញនៅការិយាល័យស្មៀនប្រចាំក្រុងនិងបណ្ណាល័យក្នុងតំបន់។
  - បិទបង្ហាញនៅអគារការិយាល័យសាលាក្រុងទាំងអស់ បណ្ណាល័យសាធារណៈ មជ្ឈមណ្ឌលសម្រាប់និវត្តជន អគារទីសក្ការៈនៅក្នុងចម្ងាយមួយម៉ាយ
- <u>សវនាការដើម្បីមតិយោបល់សាធារណៈ</u> មានលក្ខណៈហាយប្រ៊ីដ និងត្រូវបានកត់ត្រាទុក។ បុគ្គលិកទៅចូលរួមដល់ទីតាំង
- <u>គម្រោងលទ្ធភាពប្រើប្រាស់ភាសា</u> អនុវត្តលើដំណើរការទាំងអស់

# បទប្បញ្ញត្តិនៃនីតិវិធី - ការចូលរួម

## ការចូលរួមរបស់សាធារណជន

- ការចូលរួមក្នុងការដាក់ឯកសារជាមុនជាសាធារណៈ – តម្រូវឱ្យមាន
- សវនាការមតិយោបល់សាធារណៈ – មតិផ្ទាល់មាត់ និង/ឬជាលាយលក្ខណ៍អក្សរ
- ឱកាសសម្រាប់អន្តរាគមន៍ ឬស្ថានភាពអ្នកចូលរួមមានកំណត់
- កិច្ចប្រជុំក្រុមប្រឹក្សាកំណត់ទីតាំងគឺបើកចំហដល់សាធារណជន

## សាលាក្រុង និងទីភ្នាក់ងាររដ្ឋ

- ការពិគ្រោះយោបល់មុនការដាក់ឯកសារ – តម្រូវឱ្យមាន
- ការអន្តរាគម – ការចូលរួមពេញលេញនៅក្នុងដំណើរការរបស់ក្រុមប្រឹក្សាកំណត់ទីតាំង
- សេចក្តីថ្លែងការណ៍អំពីលក្ខខណ្ឌអនុញ្ញាតដែលបានផ្តល់អនុសាសន៍សម្រាប់ CEIF
- ដំណើរការអនុញ្ញាតរួមក្នុងមូលដ្ឋានដាច់ដោយឡែកសម្រាប់សាលាក្រុង (DOER)

# បទប្បញ្ញត្តិតាមនីតិវិធី – បទប្បញ្ញត្តិថ្មី

- <u>ឯកសារអនុលោមភាព</u> - អ្នកដាក់ពាក្យស្នើសុំតម្រូវឱ្យដាក់ព័ត៌មានអំពីការបំពេញតាមលក្ខខណ្ឌដែលត្រូវការ
  - ត្រូវតែដាក់ពាក្យនៅ EFSB និងបញ្ជីសេវាកម្ម
  - ឱកាសសម្រាប់អ្នកដែលនៅក្នុងបញ្ជីសេវាកម្មដើម្បីដាក់មតិយោបល់
  - ភាគីអាចស្នើសុំដំណើរការបន្ថែម - មន្ត្រីសវនាការនឹងសម្រេចថាតើដំណើរការបន្ថែមត្រូវការដែរឬទេ
- <u>ការផ្លាស់ប្តូរគម្រោង</u> – អ្នកដាក់ពាក្យស្នើសុំត្រូវបានតម្រូវឱ្យសាងសង់ និងដំណើរការកន្លែងរបស់ខ្លួនដោយអនុលោមតាមគ្រប់លក្ខណៈទាំងអស់នៃសំណើរបស់ខ្លួន ដូចដែលបានបង្ហាញដល់ក្រុមប្រឹក្សាកំណត់ទីតាំង។
  - អ្នកដាក់ពាក្យ ឬអ្នកស្នងផលប្រយោជន៍បន្តរបស់ខ្លួន ត្រូវបានទាមទារឱ្យជូនដំណឹងដល់ក្រុមប្រឹក្សាភិបាលអំពីការផ្លាស់ប្តូរណាមួយក្រៅពីការប្រែប្រួលបន្តិចបន្តួចនៅក្នុងសំណើ ដូច្នេះហើយក្រុមប្រឹក្សាកំណត់ទីតាំងអាចសម្រេចថា តើត្រូវការស៊ើបអង្កេតបន្ថែមលើបញ្ហាដាក់លាក់ណាមួយឬអត់។
  - ត្រូវតែដាក់ពាក្យអំពីការផ្លាស់ប្តូរគម្រោងជាមួយ EFSB និងបញ្ជីសេវាកម្ម
  - ឱកាសសម្រាប់អ្នកដែលនៅក្នុងបញ្ជីសេវាកម្មដើម្បីដាក់មតិយោបល់
  - នាយកនឹងកំណត់ថាតើព័ត៌មានបន្ថែម ឬដំណើរការត្រូវបានតម្រូវដែរឬទេ។
- <u>ការបញ្ឈប់ការប្រើប្រាស់ និងការស្តារទីតាំងឡើងវិញ</u>
  - កំណត់ថាអ្វីខ្លះចេញត្រូវយក និងកំណត់ពេលសម្រាប់ការងារទាំងនោះ។
  - ការប៉ាន់ស្មានការចំណាយ - វិធីដោះស្រាយដើម្បីធានាថាមូលនិធិអាចរកបាននៅចុងបញ្ចប់អាយុកាលមានប្រយោជន៍របស់ហេដ្ឋារចនាសម្ព័ន្ធដើម្បីបញ្ចប់ការបញ្ឈប់ការប្រើប្រាស់

# បទប្បញ្ញត្តិថ្មីសម្រាប់លិខិតអនុញ្ញាតរួម
# 980 CMR 13.00

- សម្រាប់នីតិវិធីអនុលោមតាមច្បាប់ G.L. ផ្នែក 164 ផ្នែក 69T, 69U, 69V។
- <u>លិខិតអនុញ្ញាតរួម</u> – សម្រាប់ CEIF ធំ និងតូច

  ជាទូទៅ៖
  - គម្រោងខ្នាតធំ – ការអនុញ្ញាតពីក្រុមប្រឹក្សាកំណត់ទីតាំង។
  - គម្រោងខ្នាតតូច - លិខិតអនុញ្ញាតរួមកម្រិតមូលដ្ឋាន ដោយមានករណីលើកលែងមួយចំនួន។
- អនុវត្តចំពោះ CEIF មជ្ឈមណ្ឌល “កេរដំណែល” របស់ EFSB នៅតែឆ្លងកាត់ដំណើរការស្តង់ដារ។
- បរិក្ខារបញ្ជូន និងចែកចាយថាមពលតូចៗ អាចមកកាន់ក្រុមប្រឹក្សាកំណត់ទីតាំង (ពេលបង្ហាញពីមូលហេតុសមរម្យ) ដើម្បីទទួលបានលិខិតអនុញ្ញាតរួម។ ច្បាប់ G.L. ជំពូកទី 164, § 69U។
- ទីតាំងផលិតថាមពលខ្នាតតូច និងទីតាំងរក្សាទុកថាមពលខ្នាតតូចអាចមក EFSB ដើម្បីទទួលបានការអនុញ្ញាតរួមពីរដ្ឋ។ ច្បាប់ G.L. ជំពូកទី 164, § 69V។
- CEIF ខ្នាតតូចអាចមកកាន់ EFSB សម្រាប់ការវិនិច្ឆ័យ de novo (សូមមើល 980 CMR 14.00)

# ការអនុញ្ញាតជារួម 980 CMR 13.00

- តម្រូវឱ្យក្រុមប្រឹក្សាកំណត់ទីតាំងកំណត់ថា៖
  - សំណុំស្តង់ដាមានលក្ខណៈដូចគ្នា
  - ការដាក់ពាក្យស្នើសុំស្តង់ដាជម្មតា
  - លក្ខខណ្ឌអនុញ្ញាតស្តង់ដា
  - ស្តង់ដាសម្រាប់អនុវត្តការវិភាគផលប៉ះពាល់រួម និងលក្ខណៈវិនិច្ឆ័យសមស្របរបស់ទីតាំង។
  - កំណត់អត្តសញ្ញាណអង្គភាពដែលទទួលខុសត្រូវចំពោះការអនុលោមភាព និងការអនុវត្តលក្ខខណ្ឌអនុញ្ញាត
- ការពិចារណាពិសេស៖
  - ការកំណត់ភាពពេញលេញដោយបុគ្គលិក (ចាប់ផ្តើមពេលវេលាសម្រាប់រយៈពេលវិនិច្ឆ័យ)។
  - សេចក្តីថ្លែងការណ៍អំពីលក្ខខណ្ឌអនុញ្ញាតដែលបានផ្តល់អនុសាសន៍ដោយទីភ្នាក់ងារអនុញ្ញាត។
  - លិខិតអនុម័តលើការសាងសង់ – ប្រសិនបើកាលបរិច្ឆេទកំណត់មិនត្រូវបានបំពេញតាម។
  - ការអនុវត្តលក្ខខណ្ឌអនុញ្ញាតត្រលប់ទៅទីភ្នាក់ងារអនុញ្ញាតវិញ។

# គំនូសតាងដំណាក់កាលនីតិវិធីរបស់ EFSB

## ដំណើរការរយៈពេល 15 ខែរបស់ EFSB

➤= ចន្លោះពេលពាក្យសុំ

*អាចអនុវត្តបានចំពោះបរិក្ខារហេដ្ឋារចនាសម្ព័ន្ធផលិតថាមពលស្អាតទ្រង់ទ្រាយធំ (ឧទាហរណ៍)៖*

- *បណ្តាញខ្សែបញ្ជូនថ្មី (≥69 kV) នៅក្នុងច្រករបៀងថ្មី (≥1 ម៉ាយល៍)*
- *បណ្តាញខ្សែបញ្ជូនថ្មី (≥115 kV) នៅក្នុងច្រករបៀងដែលមានស្រាប់ (≥10 ម៉ាយល៍)*
- *ស្ថានីយ៍រងដែលតម្រូវឱ្យមានការលើកលែងពីបទបញ្ញត្តិកំណត់តំបន់ក្នុងមូលដ្ឋាន*
- *បណ្តាញខ្សែតភ្ជាប់សម្រាប់បរិក្ខារទួរប៊ីនខ្យល់នៅឯនាយសមុទ្រ*
- *បរិក្ខារផ្ទុកថាមពលទ្រង់ទ្រាយធំ (≥100 MWh)*
- *បរិក្ខារផលិតថាមពលស្អាតទ្រង់ទ្រាយធំ (≥25 MW)*

## ដំណើរការរយៈពេល 12 ខែរបស់ EFSB

*អាចអនុវត្តបានចំពោះបរិក្ខារហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយថាមពលស្អាតទ្រង់ទ្រាយតូច (ឧទាហរណ៍)៖*

- *គម្រោងជួសជុល និងសាងសង់ឡើងវិញនូវបណ្តាញខ្សែបញ្ជូន*
- *បណ្តាញខ្សែបញ្ជូនថ្មី/ដែលបានផ្លាស់ប្តូរសំខាន់ៗនៅក្នុងច្រករបៀងដែលមានស្រាប់ (<10 ម៉ាយល៍)*
- *បណ្តាញខ្សែបញ្ជូនដែលបានបញ្ជូនថ្មី/សំខាន់ៗនៅក្នុងច្រករបៀងថ្មី (<1 ម៉ាយល៍)*
- *ស្ថានីយ៍រងដែលមិនតម្រូវឱ្យមានការលើកលែងពីបទបញ្ញត្តិកំណត់តំបន់ក្នុងមូលដ្ឋាន*
- *គម្រោងកម្រិតចែកចាយជាក់លាក់ (កម្រិតដែលត្រូវកំណត់ដោយ DOER)*




*EFSB – ក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបរិក្ខារថាមពល*

# បទប្បញ្ញត្តិថ្មី៖ ការវិនិច្ឆ័យសាជាថ្មី
# 980 CMR 14.00

- តើការវិនិច្ឆ័យសាជាថ្មីគឺជាអ្វី? ដំណើរការនេះកើតឡើងនៅពេលដែលមានសំណើឱ្យក្រុមប្រឹក្សាកំណត់ទីតាំងពិនិត្យមើលឡើងវិញនូវ សេចក្តីសម្រេចរបស់សាលាក្រុងស្តីពីលិខិតអនុញ្ញាតរួមកម្រិតមូលដ្ឋាន ឬនៅពេលដែលសាលាក្រុងខ្វះធនធានដើម្បីពិនិត្យមើលពាក្យស្នើសុំលិខិតអនុញ្ញាតរួមក្នុងរយៈពេលដប់ពីរខែ។
- តើអ្នកណាអាចស្នើសុំការវិនិច្ឆ័យសាជាថ្មីសម្រាប់ពាក្យសុំលិខិតអនុញ្ញាតកម្រិតមូលដ្ឋាន (ដោយអនុលោមតាមច្បាប់ G.L. ជំពូកទី 164 ផ្នែក 69W)៖
  - (1) ម្ចាស់ ឬអ្នកគាំទ្របរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច ដែលបានទទួលការសម្រេចចិត្តចុងក្រោយលើ ឬលិខិតអនុម័តលើការសាងសង់ លើពាក្យស្នើសុំលិខិតអនុញ្ញាតរួមពីរដ្ឋាភិបាលក្នុងមូលដ្ឋាន ហើយនិង
  - (2) ភាគីដែលរងផលប៉ះពាល់ខ្លាំង និងជាក់លាក់ពីការសម្រេចចិត្តរបស់រដ្ឋាភិបាលមូលដ្ឋាន ឬលិខិតអនុម័តលើការសាងសងដោយស្វ័យប្រវត្តិកម្រិតមូលដ្ឋាន។
- រដ្ឋាភិបាលមូលដ្ឋានអាចស្នើសុំឱ្យក្រុមប្រឹក្សាភិបាលផ្តល់ការវិនិច្ឆ័យសាឡើងវិញ - នៅពេលបង្ហាញថាធនធាន សមត្ថភាព និងបុគ្គលិកក្នុងមូលដ្ឋានមិនអនុញ្ញាតឱ្យពិនិត្យវាយតម្លៃពាក្យសុំលិខិតអនុញ្ញាតសម្រាប់បរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូចក្នុងរយៈពេលអតិបរមា 12 ខែសម្រាប់ការពិនិត្យឡើងវិញរបស់រដ្ឋាភិបាលមូលដ្ឋាន
- នីតិវិធី៖
  - សេចក្តីជូនដំណឹង និងឱកាសដើម្បីផ្តល់យោបល់ សវនាការផ្តល់យោបល់ជាសាធារណៈតាមប្រព័ន្ធនិម្មិតដែលអាចធ្វើទៅបាន
  - ការអន្តរាគម
  - កំណត់ត្រាភស្តុតាង
  - ស្តង់ដារ៖ (a) សមស្របតាមបទប្បញ្ញត្តិដែលអនុម័តស្តង់ដាអនុញ្ញាតនៅទូទាំងរដ្ឋសម្រាប់បរិក្ខារប្រភេទនេះដែលបង្កើតឡើងដោយនាយកដ្ឋានធនធានថាមពលដោយអនុលោមតាមច្បាប់ G.L. ជំពូកទី 25A, § 21; និង (b) សមស្របតាមច្បាប់ G.L. ជំពូកទី 164, § 69H។
- ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាកំណត់ទីតាំង - 6 ខែ / 12 ខែ - អាចប្តឹងឧទ្ធរណ៍ទៅតុលាការកំពូល

# ការលុបចោលបទប្បញ្ញត្តិនានាដែលមិនបានប្រើ

បទប្បញ្ញត្តិរបស់ក្រុមប្រឹក្សាកំណត់ទីតាំងមានផ្នែកជាច្រើនដែលលែងប្រើទៀតទេ ហើយមិនត្រូវបានប្រើដោយក្រុមប្រឹក្សាកំណត់ទីតាំងក្នុងរយៈពេលជាច្រើនឆ្នាំ។ ដើម្បីឱ្យមានភាពច្បាស់លាស់ ក្រុមប្រឹក្សាកំណត់ទីតាំងស្នើឱ្យលុបចោលផ្នែកខាងក្រោម៖

- ច្បាប់ 980 CMR 4.00 សេរីភាពព័ត៌មាន ការការពារការសម្ងាត់ពាណិជ្ជកម្ម
- ច្បាប់ 980 CMR 5.00 ការវាយតម្លៃបរិស្ថាន និងផលប៉ះពាល់បរិស្ថាន
- ច្បាប់ 980 CMR 7.00 ការព្យាករណ៍រយៈពេលវែង និងតម្រូវការបន្ថែម
- ច្បាប់ 980 CMR 8.00 សេចក្តីជូនដំណឹងអំពីចេតនាសាងសង់បរិក្ខារផ្ទុកប្រេងកាត
- ច្បាប់ 980 CMR 9.00 ការជ្រើសរើសទីតាំង ការវិភាគ និងការវាយតម្លៃតំបន់ឆ្នេរសមុទ្រ
- ច្បាប់ 980 CMR 11.00 អាជ្ញាបណ្ណរោងចក្រផលិតថាមពលវារីអគ្គិសនី

# សំណើសុំមតិយោបល់

- បទប្បញ្ញត្តិរបស់ក្រុមប្រឹក្សាកំណត់ទីតាំងដែលមានស្រាប់តម្រូវឱ្យមានការជូនដំណឹងអំពីសវនាការមតិយោបល់សាធារណៈតាមសារព័ត៌មាន។ តើក្រុមប្រឹក្សាកំណត់ទីតាំងគួរតែលុបបំបាត់តម្រូវការសម្រាប់ការជូនដំណឹងអំពីសវនាការមតិយោបល់សាធារណៈតាមសារព័ត៌មានដែរឬទេ? តើការជូនដំណឹងប្រភេទណាដែលមានប្រសិទ្ធភាពជាងសម្រាប់សវនាការទាំងនេះ?
- តើដំណើរទស្សនកិច្ចទៅកាន់ទីតាំងគម្រោងដែលបានស្នើឡើងរបស់បុគ្គលិករបស់ក្រុមប្រឹក្សាកំណត់ទីតាំងគួរបើកចំហជាសាធារណៈដែរឬទេ? តើក្រុមប្រឹក្សាកំណត់ទីតាំងនឹងគ្រប់គ្រងដំណើរការបែបនេះដោយរបៀបណា?
- តើក្រុមប្រឹក្សាកំណត់ទីតាំងគួរឆ្លុះបញ្ចាំងពីសកម្មភាព និងការរំពឹងទុកពីការបញ្ឈប់ការប្រើប្រាស់យ៉ាងដូចម្ដេច?
- នៅពេលដែលរដ្ឋាភិបាលមូលដ្ឋានបានបង្ហាញថាធនធាន សមត្ថភាពនិងបុគ្គលិករបស់ខ្លួនមិនអនុញ្ញាតឱ្យមានការពិនិត្យវាយតម្លៃពាក្យស្នើសុំលិខិតអនុញ្ញាតដល់បរិក្ខារហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូចបាន ក្នុងរយៈពេលអតិបរមា 12 ខែសម្រាប់ការពិនិត្យវាយតម្លៃដោយរដ្ឋាភិបាលមូលដ្ឋាន តើអាចស្នើសុំការវិនិច្ឆ័យសាឡើងវិញពីប្រធានក្រុមប្រឹក្សាកំណត់ទីតាំងដែរឬទេប្រសិនបើក្រុមប្រឹក្សាកំណត់ទីតាំងកំណត់កាលវិភាគ 12 ខែសម្រាប់ការពិនិត្យឡើងវិញស្របតាមកាលវិភាគ 12 ខែដែលអនុញ្ញាតឱ្យពិនិត្យឡើងវិញនៅកម្រិតមូលដ្ឋាន?
- សម្រាប់ការវិនិច្ឆ័យសាជាថ្មី តើបទប្បញ្ញត្តិរបស់ក្រុមប្រឹក្សាកំណត់ទីតាំងគួរផ្ដល់ឱកាសដល់សំណើសុំពិចារណាឡើងវិញដោយនាយកទទួលបន្ទុកការសម្រេចចិត្តចុងក្រោយសម្រាប់ការវិនិច្ឆ័យ សាជា ថ្មីនេះដែរឬទេ?
- នីតិវិធីផ្ដល់លិខិតអនុញ្ញាតសម្រាប់បរិក្ខារថាមពលនៅក្នុងរដ្ឋផ្សេងទៀតរួមមានជំហានដែលកំណត់វិសាលភាព ដែលអាចត្រូវបានស៊ើបអង្កេតក្នុងអំឡុងពេលធ្វើការវិនិច្ឆ័យ និងសម្រេចលើការអនុញ្ញាតចុងក្រោយ។ ការកំណត់នេះអាចបង្កើនប្រសិទ្ធភាពដល់ការចេញលិខិតអនុញ្ញាត។ តើក្រុមប្រឹក្សាកំណត់ទីតាំងគួរប្រកាន់យកការអនុវត្តបែបនេះដែរឬទេ? តើក្រុមប្រឹក្សាកំណត់ទីតាំងគួរពិចារណាលើការដាក់កម្រិតដល់ការអនុវត្តអ្វីខ្លះ? ពិពណ៌នាអំពីឧបសគ្គផ្លូវច្បាប់ណាមួយចំពោះក្រុមប្រឹក្សាកំណត់ទីតាំងក្នុងការអនុម័តការអនុវត្តស្រដៀងគ្នា។

# បទប្បញ្ញត្តិនៃនីតិវិធី

## សំណួរ ចម្លើយ ការពិភាក្សា

# កិច្ចប្រជុំនឹងបន្តឡើងវិញ នៅម៉ោង 2:50 រសៀល។

# លក្ខខណ្ឌស្តង់ដា (1) – តម្រូវការពីច្បាប់អាកាសធាតុឆ្នាំ 2024

- កាលកំណត់តាមច្បាប់ថ្មីសម្រាប់ការពិនិត្យវាយតម្លៃរបស់ EFSB លើ CEIF បន្ទាប់ពីគម្រោងទទួលបានលិខិតអនុម័តលើការសាងសង់ហើយនោះ
- លិខិតអនុម័តលើការសាងសង់អនុញ្ញាតឱ្យ CEIF បន្តទៅសាងសង់
- លិខិតអនុម័តលើការសាងសង់នឹងរួមបញ្ចូលលក្ខខណ្ឌអនុញ្ញាតស្តង់ដាជំនួសឱ្យលក្ខខណ្ឌជាក់លាក់របស់ EFSB តាមប្រភេទគម្រោង
- ទីភ្នាក់ងារផ្តល់លិខិតអនុញ្ញាតដើមនឹងអនុវត្តលក្ខខណ្ឌដែលអាចអនុវត្តបាននៅក្នុងលិខិតអនុញ្ញាតរួម

# លក្ខខណ្ឌស្តង់ដា (2) – ទិដ្ឋភាពទូទៅនៃសំណើ

- លក្ខខណ្ឌស្តង់ដានឹងរួមបញ្ចូលលក្ខខណ្ឌរបស់លិខិតអនុម័តលើការសាងសង់ ដែលតម្រូវឱ្យមាន
- លក្ខខណ្ឌស្តង់ដាដំបូងដែលដកស្រង់ចេញពីការសម្រេចចិត្តរបស់ EFSB/បទប្បញ្ញត្តិ DPU ពីមុនវិញ្ញាបនបត្រ MEPA និងបទប្បញ្ញត្តិគោលនយោបាយនិងច្បាប់ដែលមានស្រាប់ (ឧទាហរណ៍ SMART)
- លក្ខខណ្ឌក៏នឹងឆ្លុះបញ្ចាំងពីការតម្រូវនៃច្បាប់ថ្មីរបស់ EFSB ផងដែរ
- បុគ្គលិកក៏នឹងទាក់ទងទីភ្នាក់ងារផ្តល់លិខិតអនុញ្ញាតផ្សេងទៀតក្នុងពេលឆាប់ៗផងដែរសម្រាប់លក្ខខណ្ឌស្តង់ដាដែលបានស្នើឡើងដើម្បីបន្ថែមទៅក្នុងបញ្ជីនេះ
- កម្រិតទាំងបីនៃប្រភេទលក្ខខណ្ឌស្តង់ដា
  - កម្រិត 1 – លក្ខខណ្ឌស្តង់ដាកម្រិតសកល
  - កម្រិតទី 2 – លក្ខខណ្ឌការអនុម័តលើការសាងសង់
  - កម្រិតទី 3 – លក្ខខណ្ឌបច្ចេកវិទ្យាឯកទេស

# លក្ខខណ្ឌស្តង់ដា (3) – ឧទាហរណ៍លក្ខខណ្ឌ

- កម្រិត 1 – លក្ខខណ្ឌស្តង់ដាកម្រិតសកល
  - លក្ខខណ្ឌស្តង់ដាដែលនឹងអនុវត្តចំពោះគម្រោងទាំងអស់
  - ឧ. ការអនុលោមតាមគោលនយោបាយរបស់រដ្ឋ ព័ត៌មានលម្អិតអំពីការផ្សព្វផ្សាយអំពីការសាងសង់ តម្រូវការម៉ោងធ្វើការ
- កម្រិតទី 2 – លក្ខខណ្ឌការអនុម័តលើការសាងសង់
  - លក្ខខណ្ឌដែលអនុវត្តចំពោះលិខិតអនុម័តលើការសាងសង់
  - ឧ. ការផ្លាស់ប្តូរដីនៅតំបន់ដីលិចទឹកតាមលក្ខខណ្ឌ ព័ត៌មានលម្អិតអំពីផែនការឆ្លើយតបបន្ទាន់ ការត្រួតពិនិត្យការកើនឡើងកម្រិតទឹកសមុទ្រ
- កម្រិតទី 3 – លក្ខខណ្ឌបច្ចេកវិទ្យាឯកទេស
  - លក្ខខណ្ឌដែលនឹងអនុវត្តចំពោះការសម្រេចចិត្តលើបច្ចេកវិទ្យាជាក់លាក់
  - ឧ. ការផ្ទេរថាមពលអគ្គិសនីពីផ្ទៃរទៅនាវា ការធ្វើតេស្តបញ្ជាក់ដែនម៉ាញ៉េទិច ព័ត៌មានលម្អិតអំពីផែនការសុវត្ថិភាពរបស់អាគុយ

# លក្ខខណ្ឌស្តង់ដា (4) – សំណួរ

- តើលក្ខខណ្ឌស្តង់ដាសកលអ្វីខ្លះ (កម្រិត 1) ដែលអ្នកផ្តល់អនុសាសន៍សម្រាប់ការដាក់បញ្ចូលនៅក្នុងការអនុញ្ញាតរបស់ក្រុមប្រឹក្សាកំណត់ទីតាំងរួមគ្នានាពេលអនាគត?
- តើលក្ខខណ្ឌរបស់លិខិតអនុម័តលើការសាងសង់អ្វីខ្លះ (កម្រិត 2) ដែលអ្នកផ្តល់អនុសាសន៍សម្រាប់ការដាក់បញ្ចូលនៅក្នុងការអនុញ្ញាតរួមគ្នារបស់ EFSB នាពេលអនាគតតាមរយៈលិខិតអនុម័តលើការសាងសង់?
- តើលក្ខខណ្ឌបច្ចេកវិទ្យាឯកទេសអ្វីខ្លះ (កម្រិត 3) ដែលអ្នកផ្តល់អនុសាសន៍សម្រាប់ការដាក់បញ្ចូលនៅក្នុងការអនុញ្ញាតរួមគ្នារបស់ EFSB នាពេលអនាគតតាមរយៈការអនុម័តលើការសាងសង់?
    - តើមធ្យោបាយណាដែលល្អបំផុតដើម្បីទទួលបានមតិកែលម្អលើលក្ខខណ្ឌជាក់លាក់ពីភាគីពាក់ព័ន្ធ?
- តើអ្នកនឹងស្នើឱ្យក្រុមប្រឹក្សាកំណត់ទីតាំងពិចារណាលើសេចក្តីថ្លែងការណ៍ជាក់លាក់ក្នុងគម្រោងរបស់ទីភ្នាក់ងារដោយរបៀបណា ក្នុងករណីមានការអនុម័តលើការសាងសង់ហើយ?
- តើលក្ខខណ្ឌអនុញ្ញាតស្តង់ដាគួរត្រូវបានកែលម្អ ឬគួរតែផ្តល់ជម្រើសសមស្របនានាដែរឬទេ នៅកន្លែងដែលអាចអនុវត្តទៅបាន?

# លក្ខខណ្ឌស្តង់ដា

## សំណួរ ចម្លើយ ការពិភាក្សា

# សំណួរ ចម្លើយ ការពិភាក្សាទូទៅ

www.mass.gov/climateact

sitingboard.filing@mass.gov (DPU/EFSB)
energypermitting@mass.gov (EEA)
doer.siting.permitting@mass.gov (DOER)

# វគ្គប្រជុំសម្រាប់ភាគីពាក់ព័ន្ធនាពេលខាងមុខ

- វគ្គប្រជុំទី 2 សម្រាប់ភាគីពាក់ព័ន្ធ (ថ្ងៃទី 17 ខែមេសា **ម៉ោង 1-4 រសៀល**) ៖ **ពាក្យស្នើសុំថ្មី**
  - និម្មិត៖ https://www.zoomgov.com/j/1610000543
- វគ្គប្រជុំទី 3 របស់ភាគីពាក់ព័ន្ធ (ថ្ងៃទី 24 ខែមេសា ម៉ោង **5:30-8:30 យប់** Roxbury) ៖ **ការចូលរួមក្នុងការដាក់ឯកសារជាមុន កម្មវិធីជំនួយគាំទ្រអន្តរការី គោលការណ៍ណែនាំអំពីគម្រោងអត្ថប្រយោជន៍សហគមន៍**
  - លក្ខណ:ហាយប្រ៊ីដ៖ មហាវិទ្យាល័យ Roxbury Community College បន្ទប់សិស្សទូទៅលេខ 3, 1234 Columbus Avenue, Roxbury, MA 02120
- វគ្គប្រជុំទី 4 របស់ភាគីពាក់ព័ន្ធ (ថ្ងៃទី 5 ខែឧសភា ម៉ោង **5:30-8:30 យប់** នៅ **Holyoke) ៖ ការវិភាគផលប៉ះពាល់រួម លក្ខណ:វិនិច្ឆ័យភាពសមស្របរបស់ទីតាំងគម្រោង**
  - លក្ខណហាយប្រ៊ីដ៖ Holyoke Heritage State Park, 221 Appleton Street, Holyoke, MA 01040

- https://www.mass.gov/climateact